(២២)

# ប្រកាសស្តីពី

# នីតិវិធីនៃការគ្រប់គ្រងវិទ្យុចំណូល សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

លេខៈ ១៨៩០ សហវ.ប្រក

ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៤៥០ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ [illegible] ឆ្នាំ២០១៥

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការគ្រប់គ្រងវត្ថុនិយ័តទំនិញ

## សម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥

# ប្រកាស

## ស្តីពី

## នីតិវិធីនៃការគ្រប់គ្រងវិនិយោគចំណូល
## សម្រាប់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សេចក្តីសម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

ប្រការ១.-

ប្រកាសនេះ មានគោលដៅកំណត់នីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រការ២.-

ប្រកាសនេះមានគោលបំណងលើកកំពស់ ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងភាពទាន់ពេលវេលា នៃការគ្រប់គ្រងរជ្ជទេយ្យចំណូល។

ប្រការ៣.-

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងរជ្ជទេយ្យចំណូល។

## ជំពូកទី២

## ការបង្កើតរជ្ជទេយ្យចំណូល និងការតែងតាំងរជ្ជទេយ្យករចំណូល

### ផ្នែកទី១

### ការបង្កើតរជ្ជទេយ្យចំណូល

ប្រការ៤.-

រជ្ជទេយ្យចំណូលគឺជាចំណូលមិនមែនសារពើពន្ធ ដែលមានលក្ខណៈជាប្រចាំ មានចំនួនទឹកប្រាក់តិច ពុំមានកិច្ចសន្យា និងត្រូវបានបង់ផ្ទាល់ដល់រជ្ជទេយ្យករចំណូលជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬតាមរយៈគណនីរបស់រជ្ជទេយ្យករចំណូលនៅតាមធនាគារវេតន៍ ក្រោយទទួលបានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មុខសញ្ញានៃរជ្ជទេយ្យចំណូល មានជាអាទិ៍៖

- ផលដែលទទួលនៅពេលប្រគល់ឯកសារជាផ្លូវការ ឬក្នុងការបំពេញបែបបទផ្សេងៗ
- ផលបានមកពីការលក់ឯកសារនិងសម្ភារៈផ្សេងៗ
- សិទ្ធិចូល(សកម្មភាព ភាពយន្ត ទេសចរណ៍ វប្បធម៌)
- ចំណូលបានមកពីការត្រួតពិនិត្យ ឬការងារបានបំពេញ
- សំណងតម្លៃសេវាកម្មដែលបានផ្តល់
- ពិន័យពីបទល្មើសចរាចរ និងបទល្មើសផ្សេងៗទៀត
- ចំណូលផ្សេងៗដែលកំណត់ដោយច្បាប់និងបទបញ្ញត្តិជាធរមាន។

ដោយឡែក ពន្ធ សិទ្ធិ និងអាករ ដែលមានលក្ខណៈជាសារពើពន្ធ មិនអាចប្រមូលបានតាមរយៈរជ្ជទេយ្យករបានទេ លើកលែងតែមានបទប្បញ្ញត្តិដែលយល់ព្រមដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រការ៥.-

រជ្ជទេយ្យចំណូលត្រូវបានបង្កើតឡើង០១ឆ្នាំម្តង នៅរៀងរាល់ដើមឆ្នាំថវិកានីមួយៗ។

ចំពោះរដ្ឋបាលថ្នាក់ជាតិ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈប្រហាក់ប្រហែល ដែលមានបំណងបង្កើតរដ្ឋទេយ្យចំណូល ត្រូវធ្វើសំណើទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ដោយភ្ជាប់មកជាមួយនូវសេចក្តីព្រាងប្រកាសអន្តរក្រសួង (គំរូឧបសម្ព័ន្ធទី១នៃប្រកាសនេះ)។

ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ ការបង្កើតរដ្ឋទេយ្យចំណូល ត្រូវបានកំណត់ដូចខាងក្រោម៖

- សម្រាប់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត (គំរូឧបសម្ព័ន្ធទី២នៃប្រកាសនេះ) តាមរយៈរតនាគាររាជធានី ខេត្ត
- សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ (គំរូឧបសម្ព័ន្ធទី២នៃប្រកាសនេះ) តាមរយៈរតនាគាររាជធានី ខេត្ត
- សម្រាប់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់មេឃុំ ចៅសង្កាត់ (គំរូឧបសម្ព័ន្ធទី២នៃប្រកាសនេះ) តាមរយៈរតនាគាររាជធានី ខេត្ត។

## ផ្នែកទី២
## ការតែងតាំងរដ្ឋទេយ្យករចំណូល

**ប្រការ៦.-**

រដ្ឋទេយ្យករចំណូល អាចមានរដ្ឋទេយ្យករចំណូលរងមួយចំនួនជាជំនួយការ តាមការចាំបាច់។

ចំពោះរដ្ឋបាលថ្នាក់ជាតិ រដ្ឋទេយ្យករចំណូលនិងរដ្ឋទេយ្យករចំណូលរង ត្រូវបានតែងតាំងឡើងដោយប្រកាសអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ឬអង្គភាពសាធារណៈសាមី តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ (គំរូឧបសម្ព័ន្ធទី១នៃប្រកាសនេះ)។

ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ ការតែងតាំងរដ្ឋទេយ្យករចំណូលនិងរដ្ឋទេយ្យករចំណូលរង ត្រូវបានកំណត់ដូចខាងក្រោម៖

- សម្រាប់រដ្ឋបាលរាជធានី ខេត្ត ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត (គំរូឧបសម្ព័ន្ធទី២នៃប្រកាសនេះ) តាមរយៈរតនាគាររាជធានី ខេត្ត
- សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ (គំរូឧបសម្ព័ន្ធទី២នៃប្រកាសនេះ) តាមរយៈរតនាគាររាជធានី ខេត្ត
- សម្រាប់រដ្ឋបាលឃុំ សង្កាត់ ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់មេឃុំ ចៅសង្កាត់ (គំរូឧបសម្ព័ន្ធទី២នៃប្រកាសនេះ) តាមរយៈរតនាគាររាជធានី ខេត្ត។

រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង ត្រូវជ្រើសរើសយកមន្ត្រីរាជការណាដែលមានលក្ខណៈសម្បត្តិល្អ និងមានការយល់ដឹងច្បាស់លាស់អំពីកិច្ចបញ្ជិកាគណនេយ្យ ដែលអាចគ្រប់គ្រងរដ្ឋទេយ្យចំណូលបានត្រឹមត្រូវ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ផ្នែកទី៣
## ការទទួលខុសត្រូវរបស់រដ្ឋទេយ្យករចំណូល

**ប្រការ៧.-**

អនុលោមតាមមាត្រា២៥ នៃអនុក្រឹត្យលេខ៨២ អ.ន.ក្រ/ប.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ រដ្ឋទេយ្យករចំណូល និងរដ្ឋទេយ្យករចំណូលរង ត្រូវទទួលខុសត្រូវ ផ្នែករដ្ឋបាល ផ្នែកព្រហ្មទណ្ឌ ដោយផ្ទាល់ខ្លួន និងជាប្រាក់កាស ចំពោះការ

រក្សាការពារមូលនិធិ ដែលខ្លួនទទួលបាន ការរក្សាទុកដាក់លិខិតយុត្តិការ ព្រមទាំងការកាន់កាប់កិច្ចបញ្ជិកាគណនេយ្យនៃកិច្ចប្រតិបត្តិការផ្សេងៗទៀត។

## ជំពូកទី៣
## កិច្ចដំណើរការនៃរដ្ឋបាលចំណូល
### ផ្នែកទី១
### ការប្រមូលចំណូលដោយរដ្ឋទេយ្យករ

**ប្រការ៨.-**

បន្ទាប់ពីទទួលការតែងតាំងរួច រដ្ឋទេយ្យករចំណូល ត្រូវបំពេញបែបបទស្នើសុំបើកគណនី នៅអគ្គនាយកដ្ឋានរតនាគារជាតិ សម្រាប់រដ្ឋបាលថ្នាក់ជាតិ ឬនៅរតនាគាររាជធានី ខេត្ត សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ចំពោះរដ្ឋបាលថ្នាក់ជាតិ រដ្ឋទេយ្យករចំណូល ត្រូវប្រគល់ប្រកាសអន្តរក្រសួងស្តីពីការតែងតាំងរដ្ឋទេយ្យករចំណូល និងប្រកាសអន្តរក្រសួងស្តីពីការបង្កើតរដ្ឋទេយ្យចំណូល ចំនួន ១ច្បាប់ ជូនអគ្គនាយកដ្ឋានរតនាគារជាតិ និង ១ច្បាប់ ជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋទេយ្យករចំណូល ត្រូវប្រគល់សេចក្តីសម្រេចស្តីពីការតែងតាំងរដ្ឋទេយ្យករចំណូល និងសេចក្តីសម្រេចស្តីពីការបង្កើតរដ្ឋទេយ្យចំណូល ចំនួន ១ច្បាប់ ជូនរតនាគារនៅរាជធានី ខេត្ត និង ១ច្បាប់ ជូនមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៩.-**

រដ្ឋទេយ្យករចំណូលអាចប្រមូលចំណូលជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬតាមរយៈគណនីរបស់រដ្ឋទេយ្យករចំណូលនៅតាមធនាគារផ្សេងៗ។

### ផ្នែកទី២
### ការបង់ប្រាក់រដ្ឋទេយ្យចំណូល

**ប្រការ១០.-**

រដ្ឋទេយ្យករចំណូលនិងរដ្ឋទេយ្យករចំណូលរង មិនត្រូវបានអនុញ្ញាតឱ្យរក្សាទុកសាច់ប្រាក់ក្នុងបេឡា ឬមូលប្បទានប័ត្រលើសពី ២ ០០០ ០០០ (ពីរលាន) រៀល ឡើយ។ រដ្ឋទេយ្យករចំណូល ត្រូវបង់ចំណូលដែលប្រមូលបានទៅគណនេយ្យករសាធារណៈតាមរយៈធនាគារផ្សេងៗ។

នៅពេលសាច់ប្រាក់ក្នុងបេឡាកើនឡើងលើសពីកម្រិតកំណត់ រដ្ឋទេយ្យករចំណូលរង ត្រូវបង់ប្រាក់រដ្ឋទេយ្យចំណូលជូនរដ្ឋទេយ្យករចំណូល ហើយរដ្ឋទេយ្យករចំណូលត្រូវចេញបង្កាន់ដៃទទួលប្រាក់ទៅឱ្យរដ្ឋទេយ្យករចំណូលរង ដើម្បីទុកជាលិខិតយុត្តិការក្នុងគណនេយ្យរបស់ខ្លួន។ ក្នុងករណីរដ្ឋទេយ្យករចំណូលរងបង់ប្រាក់រដ្ឋទេយ្យចំណូលជូនគណនេយ្យករសាធារណៈ តាមរយៈធនាគារផ្សេង រដ្ឋទេយ្យករចំណូលរងត្រូវយកប្រកាសឥណទានរបស់ធនាគារ ជូនរដ្ឋទេយ្យករចំណូលសម្រាប់ចុះកិច្ចបញ្ជិកា។

**ប្រការ១១.-**

រៀងរាល់ថ្ងៃទី២៥នៃខែនីមួយៗ គិតពីខែមករា ដល់ខែវិច្ឆិកា និងថ្ងៃទី៣១ ខែធ្នូ រដ្ឋទេយ្យករចំណូលត្រូវធ្វើសលាកប័ត្រចំណូលទៅតាមមាតិកាថវិកាទូទៅចំនួនទឹកប្រាក់ចំណូលដែលខ្លួនបានប្រមូល។ រដ្ឋទេយ្យករចំណូលត្រូវធ្វើសលាកប័ត្របង្វែរចំណូលចូលថវិកា ជាបី (០៣) ច្បាប់ ដើម្បីដាក់ជូនទៅអាណាប័កចុះហត្ថលេខា ហើយបញ្ជូនទៅគណនេយ្យករសាធារណៈ

យ៉ាងយូរត្រឹមថ្ងៃទី២៦ រៀងរាល់ខែ និងថ្ងៃទី៣១ ខែធ្នូ។ ក្រោយពីពិនិត្យថាត្រឹមត្រូវ គណនេយ្យករសាធារណៈត្រូវរៀបចំបង្កាន់ដៃចំណូលថវិកាជាតិ ចុះហត្ថលេខាបើសហៈកប៉ុន្តែហ្មត់ និងបញ្ជូនប២ ច្បាប់មករដ្ឋទេយ្យករចំណូលវិញ។

នៅពេលដែលគណនេយ្យករសាធារណៈ ពិនិត្យឃើញកំហុសឆ្គងលើទឹកប្រាក់ក្នុងសលាកប័ត្រ នោះគណនេយ្យករសាធារណៈ និងរដ្ឋទេយ្យករចំណូល ត្រូវធ្វើការផ្ទៀងផ្ទាត់គ្នាឱ្យបានត្រឹមត្រូវឡើងវិញ។ ប្រសិនបើចំនួនទឹកប្រាក់ដែលទទួលបានពីរដ្ឋទេយ្យករចំណូល មានភាពពុំត្រឹមត្រូវនោះ រដ្ឋទេយ្យករចំណូលត្រូវធ្វើបញ្ជីសម្រង់លម្អិតនៃចំនួនទឹកប្រាក់ចំណូលដែលពុំត្រឹមត្រូវនិងត្រូវផ្តល់ព័ត៌មានសព្វគ្រប់ច្បាស់លាស់ត្រឹមត្រូវ ទើបអាចធ្វើការកែតម្រូវវិញបាន។

## ផ្នែកទី៣

## វិធានការអនុវត្តពេលដំណាច់ឆ្នាំ

ប្រការ១២.–

នាពេលដំណាច់ឆ្នាំ រដ្ឋទេយ្យករចំណូលត្រូវបង់ចំណូលទាំងអស់ដែលប្រមូលបាន ជូនគណនេយ្យករសាធារណៈ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំ។

## ជំពូកទី៤

## គណនេយ្យរដ្ឋទេយ្យចំណូល

## ផ្នែកទី១

## គោលការណ៍ទូទៅ

ប្រការ១៣.–

រដ្ឋទេយ្យករចំណូលត្រូវកាន់បញ្ជីបេឡាដោយចុះកិច្ចបញ្ជិកាទ្វេភាគនូវរាល់ប្រតិបត្តិការដែលកើតឡើងប្រចាំថ្ងៃ។

បញ្ជីគណនេយ្យរបស់រដ្ឋទេយ្យករចំណូលមាន÷ ទិន្នានុប្បវត្តិទូទៅ សៀវភៅធំ និងតារាងតុល្យភាពគណនី។

- ទិន្នានុប្បវត្តិទូទៅ÷ ប្រើសម្រាប់កត់ត្រាទៅតាមលំដាប់នៃប្រតិបត្តិការប្រចាំថ្ងៃ។ ទិន្នានុប្បវត្តិទូទៅមានរៀបរាប់អំពីលេខរៀង ថ្ងៃ ខែ យោង (ប័ណ្ណចំណូល ប័ណ្ណចំណាយ...) បរិយាយ ទឹកប្រាក់ឥណពន្ធ ទឹកប្រាក់ឥណទាន។ ទិន្នានុប្បវត្តិទូទៅត្រូវបូកសរុបនៅដំណាច់ខែនីមួយៗ និងមានការចុះហត្ថលេខាបញ្ជាក់ដោយប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ សម្រាប់ថ្នាក់កណ្តាល ឬប្រធានការិយាល័យគណនេយ្យហិរញ្ញវត្ថុ សម្រាប់ថ្នាក់រាជធានី ខេត្ត។

- សៀវភៅធំ÷ ប្រើសម្រាប់កត់ត្រាប្រតិបត្តិការនីមួយៗប្រចាំថ្ងៃជាបន្តបន្ទាប់ពីដើមឆ្នាំរហូតដល់ចុងឆ្នាំ។ សៀវភៅធំត្រូវបានបូកសរុបនាដំណាច់ខែនីមួយៗ សម្រាប់ធ្វើជាមូលដ្ឋានដើម្បីរៀបចំតារាងតុល្យភាពគណនីប្រចាំខែ។

- តារាងតុល្យភាពគណនី÷ ជាតារាងរៀបរាប់សមតុល្យចលនាប្រចាំខែនៃគណនីនីមួយៗ ហើយគណនីត្រូវរៀបរាប់តាមលំដាប់ពីតូចទៅធំ។ តារាងតុល្យភាពគណនី ត្រូវចុះហត្ថលេខាបញ្ជាក់ដោយប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ សម្រាប់ថ្នាក់កណ្តាល ឬប្រធានការិយាល័យគណនេយ្យហិរញ្ញវត្ថុ សម្រាប់ថ្នាក់រាជធានី ខេត្ត រួចផ្ញើមួយច្បាប់ទៅអគ្គនាយកដ្ឋានរតនាគារជាតិ សម្រាប់ថ្នាក់កណ្តាល និងរតនាគាររាជធានី ខេត្ត សម្រាប់ថ្នាក់រាជធានី ខេត្ត។

- បញ្ជីបេឡា÷ ត្រូវចុះនូវចំណូលដែលបានទទួល និងចំណាយដែលបានដក ទៅបង់ជូនរដ្ឋទេយ្យករចំណូល ឬធនាគារ ត្រូវកត់ត្រាប្រចាំថ្ងៃ និងធ្វើការបូកសរុបប្រចាំថ្ងៃ ខែ ឆ្នាំ។

កិច្ចបញ្ជិកាគណនេយ្យនៃរដ្ឋទេយ្យចំណូល ត្រូវកត់ត្រាជាបន្តបន្ទាប់ ចាប់ពីដើមឆ្នាំរហូតដល់ដំណាច់ឆ្នាំថវិកានីមួយៗ។

## ជំពូកទី២

## កិច្ចបញ្ជិកាគណនេយ្យដែលកាន់កាប់ដោយរជ្ជទេយ្យករចំណូល

ប្រការ១៤._

បញ្ជីបេឡារបស់រជ្ជទេយ្យករចំណូលរង ត្រូវចុះកិច្ចប្រតិបត្តិការប្រចាំថ្ងៃនូវចំណូលដែលបានទទួលនិងបានដកចេញទៅបង់ជូនរជ្ជទេយ្យករចំណូល ព្រមទាំងធ្វើការផ្ទៀងផ្ទាត់ជាមួយគ្នា នាដំណាច់ខែនូវតួលេខចំណូលដែលបានបង់។ រជ្ជទេយ្យករចំណូល ត្រូវត្រួតពិនិត្យនូវទឹកប្រាក់ដែលបានទទួលជាមួយនឹងគល់បញ្ជីបង្កាន់ដៃដែលជាសក្ខីប័ត្ររបស់រជ្ជទេយ្យករចំណូលរង។

ប្រការ១៥._

គណនីទាំងឡាយដែលប្រើប្រាស់ដោយរជ្ជទេយ្យករចំណូលនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ÷ គណនីបេឡាសាច់ប្រាក់រជ្ជទេយ្យករចំណូលនៅធនាគារ(លេខ១៣០១.១) គណនីបេឡាសាច់ប្រាក់ក្នុងដៃរជ្ជទេយ្យករចំណូល (លេខ១៣០១.២)គណនីមូលប្បទានប័ត្រធ្វើបេឡានិច្ច័យ (លេខ១១១៦) គណនីចំណូលបណ្តោះអាសន្នរជ្ជទេយ្យករចំណូល(លេខ៤៧០៥៣) គណនីប្រាក់បញ្ញើមូលនិធិរជ្ជទេយ្យករចំណូលនៅរតនាគារ (លេខ១២០៧)និងគណនីចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ១៥០៥៨) ។

ប្រការ១៦._

កិច្ចបញ្ជិកាគណនេយ្យដែលកាន់កាប់ដោយរជ្ជទេយ្យករចំណូលមានដូចតទៅ÷

ករណីរជ្ជទេយ្យករចំណូលគ្មានគណនីនៅធនាគារ:

- ការទទួលចំណូលជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ

ឥណពន្ធ គណនីបេឡាសាច់ប្រាក់ក្នុងដៃរជ្ជទេយ្យករចំណូល (លេខ១៣០១.២) ឬគណនីមូលប្បទានប័ត្រធ្វើបេឡានិច្ច័យ (លេខ១១១៦)

ឥណទាន គណនីចំណូលបណ្តោះអាសន្នរជ្ជទេយ្យករចំណូល (លេខ៤៧០៥៣)

- ការបង់ចំណូលទៅគណនេយ្យករសាធារណៈ:

ក្រោយពីទទួលប្រកាសឥណទានឬប័ណ្ណបង់ប្រាក់របស់ធនាគារ

ឥណពន្ធ គណនីប្រាក់បញ្ញើមូលនិធិរជ្ជទេយ្យចំណូលនៅរតនាគារ (លេខ១២០៧)

ឥណទានគណនីបេឡាសាច់ប្រាក់ក្នុងដៃរជ្ជទេយ្យករចំណូល (លេខ១៣០១.២) ឬគណនីមូលប្បទានប័ត្រធ្វើបេឡានិច្ច័យ(លេខ១១១៦)

- ក្រោយពីទទួលសលាកប័ត្របង់ចំណូលថវិកាពីរតនាគារ

ឥណពន្ធ គណនីចំណូលបណ្តោះអាសន្នរជ្ជទេយ្យករចំណូល (លេខ៤៧០៥៣)

ឥណទាន គណនីប្រាក់បញ្ញើមូលនិធិរជ្ជទេយ្យចំណូលនៅរតនាគារ (លេខ១២០៧)

- ករណីមានការដកប្រាក់រង្វាន់

ឥណពន្ធ គណនីចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ១៥០៥៨)

ឥណទាន គណនីបេឡាសាច់ប្រាក់ក្នុងដៃរជ្ជទេយ្យករចំណូល (លេខ១៣០១.២)

- ករណីមានការទូទាត់ប្រាក់រង្វាន់

ក្រោយពីទទួលបានដីការអមអាណត្តិបើកប្រាក់ពីរតនាគារ (ប្រាក់រង្វាន់)

ឥណពន្ធ គណនីប្រាក់បញ្ញើមូលនិធិរដ្ឋទេយ្យចំណូលនៅរតនាគារ (លេខ១៦០៧)

ឥណទាន គណនីចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ១៥០៥៤) (ប្រាក់រង្វាន់)

ក្រោយពីទទួលបានសលាកប័ត្របង់ចំណូលពីរតនាគារ (ប្រាក់រង្វាន់)

ឥណពន្ធ គណនីចំណូលបណ្ដោះអាសន្នរដ្ឋទេយ្យករចំណូល (លេខ៤៧០៥៣)

ឥណទាន គណនីប្រាក់បញ្ញើមូលនិធិរដ្ឋទេយ្យចំណូលនៅរតនាគារ (លេខ១៦០៧)

ករណីរដ្ឋទេយ្យករចំណូលមានគណនីនៅធនាគារ

- ការទទួលចំណូលជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ

ឥណពន្ធ គណនីបេឡាសាច់ប្រាក់ក្នុងដៃរដ្ឋទេយ្យករចំណូល (លេខ១៣០១.២) ឬគណនីមូលប្បទានប័ត្រធ្វើបេឡានិច្ច័យ (លេខ១១១៦)

ឥណទាន គណនីចំណូលបណ្ដោះអាសន្នរដ្ឋទេយ្យករចំណូល (លេខ៤៧០៥៣)

- ពេលរដ្ឋទេយ្យករយកសាច់ប្រាក់ ឬមូលប្បទានប័ត្របង់ចូលគណនីរបស់រដ្ឋទេយ្យករនៅធនាគារ

ឥណពន្ធ គណនីបេឡាសាច់ប្រាក់រដ្ឋទេយ្យករចំណូលនៅធនាគារ (លេខ១៣០១.១)

ឥណទាន គណនីបេឡាសាច់ប្រាក់ក្នុងដៃរដ្ឋទេយ្យករចំណូល (លេខ១៣០១.២) ឬគណនីមូលប្បទានប័ត្រធ្វើបេឡានិច្ច័យ (លេខ១១១៦)

- ការបង់ចំណូលទៅគណនេយ្យករសាធារណៈ:

ក្រោយពីទទួលប្រកាសឥណទានឬប័ណ្ណបង់ប្រាក់របស់ធនាគារ

ឥណពន្ធ គណនីប្រាក់បញ្ញើមូលនិធិរដ្ឋទេយ្យចំណូលនៅរតនាគារ (លេខ១៦០៧)

ឥណទានគណនីបេឡាសាច់ប្រាក់រដ្ឋទេយ្យករចំណូលនៅធនាគារ (លេខ១៣០១.១)

- ក្រោយពីទទួលសលាកប័ត្របង់ចំណូលថវិកាពីរតនាគារ

ឥណពន្ធ គណនីចំណូលបណ្ដោះអាសន្នរដ្ឋទេយ្យករចំណូល (លេខ៤៧០៥៣)

ឥណទាន គណនីប្រាក់បញ្ញើមូលនិធិរដ្ឋទេយ្យចំណូលនៅរតនាគារ (លេខ១៦០៧)

- ករណីមានការដកប្រាក់រង្វាន់

ឥណពន្ធ គណនីចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ១៥០៥៤)

ឥណទាន គណនីបេឡាសាច់ប្រាក់រដ្ឋទេយ្យករចំណូលនៅធនាគារ (លេខ១៣០១.១)

-ករណីមានការទូទាត់ប្រាក់រង្វាន់

ក្រោយពីទទួលបានដីការអមអាណត្តិបើកប្រាក់ពីរតនាគារ (ប្រាក់រង្វាន់)

ឥណពន្ធ គណនីប្រាក់បញ្ញើមូលនិធិរដ្ឋទេយ្យចំណូលនៅរតនាគារ (លេខ១៦០៧)

ឥណទាន គណនីចំណាយមុនការធ្វើអាណត្តិកិច្ច (លេខ១៥០៥៤) (ប្រាក់រង្វាន់)

ក្រោយពីទទួលបានសលាកប័ត្របង់ចំណូលពីរតនាគារ (ប្រាក់រង្វាន់)

ឥណពន្ធ គណនីចំណូលបណ្ដោះអាសន្នរដ្ឋទេយ្យករចំណូល (លេខ៤៧០៥៣)

ឥណទាន គណនីប្រាក់បញ្ញើមូលនិធិរដ្ឋទេយ្យចំណូលនៅរតនាគារ (លេខ១៦០៧)

## ផ្នែកទី៣
## កិច្ចបញ្ជិកាគណនេយ្យដែលកាន់កាប់ដោយគណនេយ្យករសាធារណៈ

ប្រការ១៧.–

កិច្ចប្រតិបត្តិការនៃរដ្ឋទេយ្យចំណូល ត្រូវតាមដានដោយគណនេយ្យករសាធារណៈ។ កិច្ចបញ្ជិកាគណនេយ្យដែលកាន់កាប់ដោយគណនេយ្យករសាធារណៈ មានដូចតទៅ÷

- ការបង់ជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ដោយរដ្ឋទេយ្យករចំណូល
  - ឥណពន្ធ គណនីធនាគារ ឬបេឡាសាច់ប្រាក់ (លេខ ១១០១, ១១០៥, ១១០៦, ១៣០១)
    - ឥណទាន គណនីរដ្ឋទេយ្យករចំណូល (លេខ៤៧០៤)
- ការទទួលសលាកប័ត្រចំណូលដែលមានទិដ្ឋាការរបស់អាណាប័ក
  - ឥណពន្ធ គណនីរដ្ឋទេយ្យករចំណូល (លេខ៤៧០៤)
    - ឥណទាន គណនីចំណូលថវិកា (៧.....)
- ការទូទាត់ប្រាក់រង្វាន់
  - ឥណពន្ធ គណនីចំណាយថវិកា (លេខ ៦៤០៣៣)
    - ឥណទាន គណនីរដ្ឋទេយ្យករចំណូល (លេខ៤៧០៤)
- ការទទួលសលាកប័ត្រចំណូលដែលមានទិដ្ឋាការរបស់អាណាប័ក (ប្រាក់រង្វាន់)
  - ឥណពន្ធ គណនីរដ្ឋទេយ្យករចំណូល (លេខ៤៧០៤)
    - ឥណទាន គណនីចំណូលថវិកា (៧.....)

## ជំពូកទី៥
## ការត្រួតពិនិត្យរដ្ឋទេយ្យចំណូល
## ផ្នែកទី១
## គោលការណ៍ទូទៅ

ប្រការ១៨.–

អនុលោមតាមមាត្រា២៤ នៃអនុក្រឹត្យលេខ៨២ អ.ន.ក្រ/ប.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ រដ្ឋទេយ្យចំណូលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អាណាប័ករបស់ខ្លួន និងគណនេយ្យករមុខការ។ រដ្ឋទេយ្យចំណូលក៏ស្ថិតនៅក្រោមការផ្ទៀងផ្ទាត់របស់អធិការកិច្ចហិរញ្ញវត្ថុទូទៅ និងពីអាជ្ញាធរទាំងឡាយដែលមាននីតិសម្បទា ត្រួតពិនិត្យនៅនឹងកន្លែងចំពោះអាណាប័ក និងគណនេយ្យករមុខការដែរ។

## ផ្នែកទី២
## ការត្រួតពិនិត្យលើលិខិតយុត្តិការ

ប្រការ១៩.–

អាណាប័ក មានភារកិច្ចត្រួតពិនិត្យ ដូចតទៅ÷

- អាណាប័កតម្រូវឱ្យរដ្ឋទេយ្យករចំណូលផ្តល់នូវតារាងតុល្យភាពគណនីទាំងឡាយនៃរដ្ឋទេយ្យចំណូលប្រចាំខែប្រចាំឆ្នាំ របាយការណ៍និងកំណត់ហេតុត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែងលើការងាររដ្ឋទេយ្យចំណូល ដែលបានធ្វើឡើងដោយគណនេយ្យករមុខការ

- អាណាប័កត្រូវទទួលខុសត្រូវចំពោះការបង់ចំណូលរបស់រដ្ឋលេខាធិការចំណូលស្របនឹងសម្រង់ចំណូលប្រចាំខែនៃរដ្ឋលេខាធិការចំណូល។ អាណាប័កតម្រូវឱ្យរដ្ឋលេខាធិការចំណូលបង្ហាញនូវសៀវភៅកល់បញ្ជីបង្កាន់ដៃ ដែលបានប្រើប្រាស់ទាំងអស់ ដើម្បីផ្ទៀងផ្ទាត់ចំណូលដែលបានទទួលជាសាច់ប្រាក់។

ប្រការ២០.-

គណនេយ្យករមុខការ មានភារកិច្ចត្រួតពិនិត្យ ដូចតទៅ÷

- រដ្ឋលេខាធិការចំណូលត្រូវផ្តល់ ចំពោះគណនេយ្យករសាធារណៈនូវតារាងតុល្យភាពគណនីនៃរដ្ឋលេខាធិការចំណូល ព្រមទាំងសំណុំឯកសារ ឬព័ត៌មានស្តីពីរដ្ឋលេខាធិការចំណូល

- គណនេយ្យសាធារណៈ ត្រូវត្រួតពិនិត្យភាពប្រាកដប្រជានៃសម្រង់ចំណូលប្រចាំខែ ដែលធ្វើឡើងដោយរដ្ឋលេខាធិការចំណូល និងធានាបានជាពិសេសនូវកំណត់សំគាល់ទាំងឡាយនៃការបង់ចំណូលក្នុងខែនីមួយៗ ស្របទៅតាមគណនេយ្យរបស់ខ្លួន

- រដ្ឋលេខាធិការចំណូល ត្រូវបង្ហាញសៀវភៅកល់បញ្ជី បង្កាន់ដៃទាំងអស់ដែលបានប្រើប្រាស់ ដល់គណនេយ្យករមុខការដើម្បីធ្វើការត្រួតពិនិត្យក្នុងការបង់ចំណូលជាសាច់ប្រាក់។

## ផ្នែកទី៣
## ការត្រួតពិនិត្យដល់ទីកន្លែង

ប្រការ២១.-

គណនេយ្យករមុខការ អាណាប័ក អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ អគ្គាធិការដ្ឋានហិរញ្ញវត្ថុ និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតអាចធ្វើការត្រួតពិនិត្យនៅនឹងកន្លែងផ្ទាល់ លើការគ្រប់គ្រងរបស់រដ្ឋលេខាធិការចំណូល។ ការត្រួតពិនិត្យនេះត្រូវប្រព្រឹត្តទៅដោយមិនប្រាប់ឱ្យដឹងជាមុន។ អាណាប័កនិងគណនេយ្យករមុខការអាចចាត់ភ្នាក់ងារដែលនៅក្រោមឱវាទឱ្យចុះទៅត្រួតពិនិត្យនៅនឹងកន្លែង។ ភ្នាក់ងារត្រួតពិនិត្យនេះត្រូវមានលិខិតបញ្ជាបេសកកម្ម ឬ លិខិតឧទ្ទេសនាម។

ប្រការ២២.-

ការត្រួតពិនិត្យត្រូវផ្ទៀងផ្ទាត់ចំណុចសំខាន់ៗដូចតទៅ÷

- ការទទួលស្គាល់មូលនិធិនិងតម្លៃ
- ការបញ្ឈប់និងការចុះទិដ្ឋាការលើបញ្ជី
- ការកសាងតារាងតុល្យភាពគណនី
- ការត្រួតពិនិត្យកិច្ចប្រតិបត្តិការគណនេយ្យនិងលិខិតយុត្តិការព្រមទាំងការត្រួតពិនិត្យលក្ខខ័ណ្ឌទូទៅនៃការរៀបចំ និងកិច្ចដំណើរការរបស់រដ្ឋលេខាធិការចំណូល។

ប្រការ២៣.-

ការត្រួតពិនិត្យផ្ទាល់នៅនឹងកន្លែងដោយអាណាប័ក ឬដោយអ្នកតំណាងត្រូវធ្វើឱ្យបានញឹកញាប់បំផុត។ ជាគោលការណ៍ ការទទួលស្គាល់មូលនិធិ និងតម្លៃត្រូវធ្វើឱ្យបានម្តងក្នុងមួយត្រីមាស។ ការផ្ទៀងផ្ទាត់របស់គណនេយ្យករសាធារណៈ ត្រូវធ្វើឡើងយ៉ាងហោចណាស់មួយឆ្នាំម្តង។ រាល់ការត្រួតពិនិត្យមួយលើកៗ ត្រូវមានរបាយការណ៍ ឬកំណត់ហេតុត្រឹមត្រូវច្បាស់លាស់ ដែលក្នុងនោះត្រូវកត់សម្គាល់នូវកិច្ចការដែលបានពិនិត្យឃើញ។ ឯកសារទាំងនោះត្រូវផ្តល់ឱ្យរដ្ឋលេខាធិការចំណូលធ្វើការកត់សម្គាល់និងផ្តល់នូវចម្លើយ ហើយត្រូវផ្ញើរត្រឡប់ទៅអ្នកត្រួតពិនិត្យវិញ។ ___

# ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ២៤._**

ត្រូវបាននិរាករណ៍ លិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម៖

- ប្រកាសលេខ១៤០៥ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងកិច្ចដំណើរការគណនីនៃរដ្ឋទេយ្យចំណូល
- សារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល
- សារាចរណែនាំលេខ ០១៣ សហវ.ម ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងរដ្ឋទេយ្យចំណូល

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៥._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រតនាគាររាជធានី ខេត្ត
- ដូចប្រការ២៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

ប្រការ២៤.-

ត្រូវបាននិរាករណ៍ លិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម៖

- ប្រកាសលេខ១៨០៥ សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការរៀបចំនិងកិច្ចដំណើរការគណនីនៃរដ្ឋទេយ្យចំណូល
- សារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីរដ្ឋទេយ្យចំណូល
- សារាចរណែនាំលេខ ០១៣ សហវ.ម ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងរដ្ឋទេយ្យចំណូល

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ២៥.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

[illegible]

កន្លែងទទួល៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមុខងារសាធារណៈ

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-សាលារាជធានី ខេត្ត

-គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រតនាគាររាជធានី ខេត្ត

-ដូចប្រការ២៥

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

គំរូប្រកាសអន្តរក្រសួង ស្តីពីការតែងតាំងរដ្ឋលេខាធិការទទួលបន្ទុកចំណូលនៅក្រសួង-ស្ថាប័ន/អង្គភាព/មន្ទីររាជធានី ខេត្ត
ដែលបានអនុវត្តរដ្ឋលេខាធិការចំណូល

**ប្រកាសអន្តរក្រសួង**

**ស្តីពី**

**ការតែងតាំងរដ្ឋលេខាធិការទទួលបន្ទុកចំណូល**

**នៅក្រសួង/ស្ថាប័ន/អង្គភាព/មន្ទីររាជធានី ខេត្ត......................**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួង/ប្រធានស្ថាប័ន/ប្រធានអង្គភាព......**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/.../.. ចុះថ្ងៃទី... ខែ... ឆ្នាំ.... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង.......
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ.... ចុះថ្ងៃទី... ខែ....ឆ្នាំ.....ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ...........
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ......អនក្រ.បក ចុះថ្ងៃទី....ខែ.........ឆ្នាំ..... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង/ស្ថាប័ន/អង្គភាព
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ. ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រ.ក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រ.ក ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង/ ស្ថាប័ន/អង្គភាព.............

សម្រេច

ប្រការ១.-

ត្រូវបានតែងតាំងមន្ត្រីរាជការនៃក្រសួង/ស្ថាប័ន/អង្គភាព/មន្ទីរ....... ដូចខាងក្រោម÷

១. លោក/ លោកស្រី....(ឈ្មោះ).... មុខងារ.....ជារជ្ជទេយ្យករចំណូលអមនៅក្រសួង/ ស្ថាប័ន/ អង្គភាព/ មន្ទីរ................

២. លោក/ លោកស្រី....(ឈ្មោះ).... មុខងារ.....ជារជ្ជទេយ្យករចំណូលរងអមនៅក្រសួង/ ស្ថាប័ន/ អង្គភាព/ មន្ទីរ...........

៣.........................................................................................................................................

(តែងតាំងតាមការចាំបាច់)

ប្រការ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គាធិការ និងប្រធានគ្រប់អង្គភាពទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួង/ស្ថាប័ន/អង្គភាព...... ប្រធានគ្រប់អង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួង/ ស្ថាប័ន/អង្គភាព...... ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....ខែ......ឆ្នាំ.....

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ　　　　រដ្ឋមន្ត្រីក្រសួង/ប្រធានស្ថាប័ន...

<u>កន្លែងទទួល÷</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រតនាគាររាជធានី ខេត្ត
-ដូចប្រការ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

គំរូប្រកាសអន្តរក្រសួងស្តីពីការបង្កើតរជ្ជទេយ្យចំណូលនៅក្រសួង ស្ថាប័ន/អង្គភាព/មន្ទីរជំនាញរាជធានី ខេត្ត

ដែលបានអនុវត្តរជ្ជទេយ្យចំណូល

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតរជ្ជទេយ្យចំណូល

## នៅក្រសួង/ស្ថាប័ន/អង្គភាព/មន្ទីរជំនាញរាជធានី ខេត្ត.....................

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួង/ប្រធានស្ថាប័ន/ប្រធានអង្គភាព.........**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខន.ស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/..../.. ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង.......
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ.... ចុះថ្ងៃទី...ខែ....ឆ្នាំ.....ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ..........
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ......អនក្រ.បក ចុះថ្ងៃទី....ខែ....ឆ្នាំ.......... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួង/ស្ថាប័ន/អង្គភាព
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រ.ក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រ.ក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-បានឃើញប្រកាសលេខ ១៥៩០ សហវ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង/ស្ថាប័ន/អង្គភាព.........

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យចំណូលនៅ....ដើម្បីធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។ បញ្ជីរាយប្រភេទចំណូល ផលដែលរជ្ជទេយ្យករ ដូចខាងក្រោម ÷

១. គណនី/អនុគណនី............អត្ថន័យ........................ចំនួនទឹកប្រាក់..........................................................

២. គណនី/អនុគណនី............អត្ថន័យ........................ចំនួនទឹកប្រាក់..........................................................

៣.............................................................................................................................................

សរុបទឹកប្រាក់:........................................

**ប្រការ២.-**

ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន........................(សរសេរជាអក្សរ)។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គាធិការ និងប្រធានគ្រប់អង្គភាពទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួង/ស្ថាប័ន/អង្គភាព....... ប្រធានគ្រប់អង្គភាពក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួង/ស្ថាប័ន/អង្គភាព...... ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.....ខែ....ឆ្នាំ....

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ　　　　រដ្ឋមន្ត្រីក្រសួង/ប្រធានស្ថាប័ន...

<u>**កន្លែងទទួល÷**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់រតនាគាររាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី២

- គំរូសេចក្តីសម្រេចស្តីពីការបង្កើតវិធានទេយ្យចំណូលនៅសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតវិធានទេយ្យចំណូលសម្រាប់ឆ្នាំ.....

## នៅសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ..........

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ.... ចុះថ្ងៃទី... ខែ.... ឆ្នាំ..... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ..........
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ. ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងវិធានទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

**សម្រេច**

ប្រការ១._

ត្រូវបានបង្កើតរជ្ជទេយ្យចំណូលទៅ..... ដើម្បីធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗ។ បញ្ជីរាយប្រភេទចំណូល ដែលរជ្ជទេយ្យករត្រូវបានអនុញ្ញាតឱ្យប្រមូល៖

១. គណនី/អនុគណនី............អត្ថន័យ........................ចំនួនទឹកប្រាក់.......................................................

២. គណនី/អនុគណនី............អត្ថន័យ........................ចំនួនទឹកប្រាក់.......................................................

៣. ..........................................................................................................................................

សរុបទឹកប្រាក់:.......................................................

ប្រការ២._

ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន........................ (សរសេរជាអក្សរ)។

ប្រការ៣._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤._

សាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ...... រតនាគាររាជធានី ខេត្ត..... មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...... ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានី/ខេត្ត.... ថ្ងៃទី......ខែ........ឆ្នាំ........

**អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត/**

**ក្រុង ស្រុក ខណ្ឌ**

<u>**កន្លែងទទួល៖**</u>

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  (ជូនជ្រាប)
- ដូចប្រការ៤ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី២

គំរូសេចក្តីសម្រេចស្តីពីការតែងតាំងរជ្ជទេយ្យករចំណូលនៅសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ

សេចក្តីសម្រេច

ស្តីពី

ការតែងតាំងរជ្ជទេយ្យករចំណូល

នៅសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខន.ស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ.... ចុះថ្ងៃទី... ខែ.... ឆ្នាំ..... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ..........
- បានឃើញអនុក្រឹត្យលេខ ៨៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ. ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រ.ក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រ.ក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

**សម្រេច**

**ប្រការ១.–**

ត្រូវបានតែងតាំងមន្ត្រីរាជការនៅសាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ........... ដូចខាងក្រោម÷

1- លោក/លោកស្រី .......... .(ឈ្មោះ) ............. (មុខងារ) ជារដ្ឋលេខាធិការចំណូលនៅ....................................

2- លោក/លោកស្រី............(ឈ្មោះ) ............. (មុខងារ) ជារដ្ឋលេខាធិការចំណូលរងនៅ................................។

(តែងតាំងតាមការចាំបាច់)

**ប្រការ២.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣.–**

សាលារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ...... រតនាគាររាជធានី ខេត្ត...... មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត...... ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានី/ខេត្ត.... ថ្ងៃទី.......ខែ........ឆ្នាំ........

**អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត/**

**ក្រុង ស្រុក ខណ្ឌ**

<u>**កន្លែងទទួល÷**</u>

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
(ជូនជ្រាប)
- ដូចប្រការ៣ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី២

គំរូសេចក្ដីសម្រេចស្ដីពីការតែងតាំងរជ្ជទេយ្យករចំណូលនៅឃុំ/ សង្កាត់....

សេចក្ដីសម្រេច

ស្ដីពី

ការតែងតាំងរជ្ជទេយ្យករចំណូល

នៅឃុំ/សង្កាត់.......

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងឃុំ សង្កាត់
- បានឃើញព្រះរាជក្របលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ....ចុះថ្ងៃទី...ខែ....ឆ្នាំ.....ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ..........
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រ.ក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រ.ក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្ដីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណាយសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

## សម្រេច

ប្រការ១.-

ត្រូវបានតែងតាំងមន្ត្រីរាជការនៅឃុំ/សង្កាត់........... ដូចខាងក្រោម÷

១. លោក/លោកស្រី ..........(ឈ្មោះ) ................. (មុខងារ) ជាគណនេយ្យករចំណូលនៅ..............................

២. លោក/លោកស្រី..........(ឈ្មោះ) ..................(មុខងារ) ជាគណនេយ្យករចំណូលរងនៅ.........................។

(តែងតាំងតាមការចាំបាច់)

ប្រការ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣.-

រតនាគាររាជធានី/ខេត្ត...ឃុំ/សង្កាត់..ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅឃុំ/សង្កាត់.... ថ្ងៃទី......ខែ.....ឆ្នាំ......

មេឃុំ-ចៅសង្កាត់....

កន្លែងទទួល÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  (ជូនជ្រាប)
- ដូចប្រការ៣ (ដើម្បីមុខការ)
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី២

គំរូសេចក្តីសម្រេចស្តីពីការបង្កើតរជ្ជទេយ្យចំណូលនៅឃុំ/សង្កាត់...

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតរជ្ជទេយ្យចំណូលសម្រាប់ឆ្នាំ.....**

**នៅឃុំ/សង្កាត់..........**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខន.ស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ ន.ស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ.... ចុះថ្ងៃទី... ខែ.... ឆ្នាំ..... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ..........
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រ.ក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រ.ក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យប្រចាំឆ្នាំសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-យោងតាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបច្ចុប្បន្ន

សម្រេច

ប្រការ១._

ត្រូវបានបង្កើតរជ្ជទេយ្យចំណូលនៅ..ដើម្បីធ្វើការប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗ។ បញ្ជីរាយប្រភេទចំណូលផលដែលរជ្ជទេយ្យករត្រូវបានអនុញ្ញាតឱ្យប្រមូល ÷

១.គណនី/អនុគណនី......................អត្ថន័យ......................ចំនួនទឹកប្រាក់.............................................

២.គណនី/អនុគណនី......................អត្ថន័យ......................ចំនួនទឹកប្រាក់.............................................

៣. .......................................................................................................................................

សរុបទឹកប្រាក់:...................................................

ប្រការ២._

ចំនួនទឹកប្រាក់អតិបរមា ដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន............... (សរសេរជាអក្សរ)។

ប្រការ៣._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤._

រតនាគាររាជធានី/ខេត្ត...ឃុំ/សង្កាត់..ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅឃុំ/ សង្កាត់.... ថ្ងៃទី......ខែ.....ឆ្នាំ......

មេឃុំ-ចៅសង្កាត់....

កន្លែងទទួល÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ជូនជ្រាប)
- ដូចប្រការ៤ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ